# ពលរដ្ឋជាង ២ពាន់គ្រួសារនៅតំបន់រុនតាឯក ព្រមានរុះរើផ្ទះទៅតំបន់អង្គរវិញ បើអាជ្ញាធរពុំពន្លឿនការដោះស្រាយបញ្ហាប័ណ្ណសមធម៌



*ពលរដ្ឋជាង ២ពាន់គ្រួសារ ផ្ទុះការតវ៉ា នៅខាងមុខសាលាឃុំរុនតាឯក ខេត្តសៀមរាម ដោយសារពួកគាត់ខកចិត្ត នឹងការបើករបបឧបត្ថម្ភជនក្រីក្រ បានតែពាក់កណ្ដាល កាលពីថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៤។*

ពលរដ្ឋជាង ២.០០០គ្រួសារនៅតំបន់រុនតាឯកស្រុកបន្ទាយស្រីខេត្តសៀមរាប ព្រមានរុះរើផ្ទះសម្តែង ត្រឡប់ទៅនៅតំបន់អង្គរវិញ ប្រសិនបើអាជ្ញាធរពាក់ព័ន្ធ ពុំពន្លឿនដោះស្រាយបញ្ហាប័ណ្ណសមធមិឱ្យបានឆាប់។ មន្ត្រីសង្គមស៊ីវិលថា អាជ្ញាធរគួរតែយកបញ្ហារបស់ពលរដ្ឋ ដោះស្រាយឱ្យបានត្រឹមត្រូវ។

ពលរដ្ឋរស់នៅតំបន់រុនតាឯក ជាច្រើនគ្រួសារស្នើសុំឱ្យអាជ្ញាធរ ពន្លឿនដោះស្រាយបញ្ហាប្រាក់ដែលកាត់ពីប័ណ្ណសមធម៌ ប្រមាណជាង ២០ ទៅ ៣០ម៉ឺនរៀលក្នុងមួយគ្រួសារ។ ពលរដ្ឋថា ការកាត់នេះ ជារឿងមិនត្រឹមត្រូវ ព្រោះពេលកន្លងទៅ រដ្ឋាភិបាលបានសន្យាថានឹងផ្ដល់ឱ្យពួកគាត់រយៈពេល ១០ឆ្នាំ។

ពលរដ្ឋដែលរស់នៅតំបន់ភូមិរុនតាឯក ស្រុកបន្ទាយស្រី លោក ឡុង ឡៃន ប្រាប់វិទ្យុអាស៊ីសេរីនៅថ្ងៃទី១ ខែមករាថា ពលរដ្ឋជាង២ពាន់គ្រួសារ ពួកគាត់ពុំសប្បាយចិត្តចំពោះការកាត់ប្រាក់ពីប័ណ្ណសមធម៌ចំនួនពី ២០ ទៅ ៣០ម៉ឺនរៀលក្នុងមួយគ្រួសារនោះទេ។ លោកបន្តថា ពលរដ្ឋនឹងក្រោកតវ៉ាទ្រង់ទ្រាយធំ ហើយឈានដល់ការរុះរើផ្ទះទៅតំបន់អង្គរវិញ ប្រសិនបើអាជ្ញាធរពុំអើពើដោះស្រាយ។

លោក ឡុង ឡៃន៖ *«បើសិនខាងរដ្ឋាភិបាលនៅតែធ្វើឱ្យមានបញ្ហា ពួកគាត់នឹងតវ៉ាដែលធ្វើឱ្យរដ្ឋាភិបាលកាន់តែឈឺក្បាលខ្លាំង។ ព្រោះធម្មតាយើងរើរុះចេញពីតំបន់រមណីយដ្ឋានអង្គរ គឺយើងខាតបង់ទាំងស្រុង ទាំងដី ទាំងទ្រព្យសម្បត្តិ គឺយើងបោះបង់អស់ ហើយដល់ពេលរាជរដ្ឋាភិបាលសន្យាជាមួយយើង គាត់ធ្វើអត់បាន ប្រជាជនត្រូវតែទាមទារយកចំណុចដើរវិញហើយ»*។

ពលរដ្ឋម្នាក់ទៀត សុំមិនបញ្ចេញឈ្មោះលើកឡើងថា ចាប់តាំងពីមានការតវ៉ារបស់ពួកគាត់  ជុំវិញបញ្ហាប័ណ្ណសមធម៌នេះមក ត្រូវបានអាជ្ញាធរដើរគំរាមកំហែង ដោយប្រើពាក្យសម្ដីអសុរោះ ជេរប្រមាថ និងគំរាមបញ្ឈប់មិនឱ្យរស់នៅតំបន់រុនតាឯកតទៅទៀត  ប្រសិនបើពួកគាត់នៅតវ៉ា ហើយនិយាយនឹងសារព័ត៌មាន ដែលធ្វើឱ្យប៉ះពាល់មុខមាត់រដ្ឋាភិបាល។

ទោះយ៉ាងជាណាក្ដី ពលរដ្ឋទាំងនោះ អះអាងថា  ការគំរាមកំហែង និងដើរស្រង់ឈ្មោះពលរដ្ឋដែលទៅតវ៉ា ពុំមែនជារឿងល្អ ហើយអាចបញ្ឈប់ការឃ្លានយុត្តិធម៌

បាននោះទេ។ ពលរដ្ឋទទូចឱ្យអាជ្ញាធរពាក់ព័ន្ធ ងាកមកដោះស្រាយបញ្ហា ទើបជាមធ្យោបាយដ៏ល្អ ជាជាងការដើរគំរាមពលរដ្ឋ។

ជុំវិញរឿងនេះ វិទ្យុអាស៊ីសេរីពុំអាចទាក់ទងអភិបាលខេត្តសៀមរាប លោក ប្រាក់ សោភ័ណ និង ប្រធានអង្គភាពអ្នកនាំពាក្យរដ្ឋាភិបាល ប៉ែន បូណា បានទេ នៅថ្ងៃទី ១ ខែកុម្ភៈ ដោយសារទូរស័ព្ទហៅចូល តែគ្មានអ្នកទទួល។

អ្នកសម្របសម្រួលគម្រោងធុរកិច្ច និងសិទ្ធិមនុស្សរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា លោក វណ្ណសុផាត យល់ថា ការប្រមូលផ្តុំរបស់ប្រជាពលរដ្ឋ ដើម្បីទាមទារដំណោះស្រាយ គឺជាភាពត្រឹមត្រូវ និងស្របច្បាប់ ចំណែក រដ្ឋាភិបាលត្រូវតែយកកង្វល់របស់ពលរដ្ឋទាំងនោះ ដោះស្រាយប្រកបដោយយុត្តិធម៌ ពុំអាចគេចវេះ យកតែរូចខ្លួននោះទេ។

លោក វណ្ណសុផាត៖ *«ប័ណ្ណសមធម៌ អត់ត្រូវមានលក្ខខណ្ឌអីថា ត្រូវដកពីហ្នឹងទៅចំណាយក្នុងកម្មវិធីអីផ្សេងទៀតទេ។ បើតាមខ្ញុំដឹង ប័ណ្ណសមធម៌ គឺប័ណ្ណសមធម៌ ហើយត្រូវផ្តល់ជូនប្រជាពលរដ្ឋរយៈពេលប៉ុន្មានឆ្នាំអនុវត្តឱ្យគ្រប់លក្ខខណ្ឌរបស់គាត់»។*

នៅថ្ងៃទី២៧ មករា ពលរដ្ឋរស់នៅតំបន់រុនតាឯកជាង ២.០០០នាក់ បានជួបជាមួយរដ្ឋបាលខេត្តសៀមរាប ដូចជា មន្ត្រីសង្គមកិច្ច ព្រមទាំងអភិបាលស្រុកបន្ទាយស្រី លោក រិន ឡូត នៅផ្សាររុនតាឯកថ្មី ដែលជាកន្លែងពលរដ្ឋតវ៉ា ដើម្បីដំណោះស្រាយ រឿងកាត់ប្រាក់ប័ណ្ណសមធម៌។ ចំណែកអាជ្ញាធរបានសន្យាថា នឹងផ្តល់ឱ្យពលរដ្ឋវិញយ៉ាងយូរត្រឹមថ្ងៃទី២៧ ខែមករា តែជាក់ស្តែងពលរដ្ឋថា ពួកគាត់ពុំទាន់បានលុយទាំងនោះនៅឡើយទេ រហូតដល់ថ្ងៃទី១ ខែកុម្ភៈ៕